ASEAN SME Academy

# ប្រឈមមុខជាមួយ
# បញ្ហារបស់លោកអ្នក។
# ធ្វើឲ្យសហគ្រាស
# លោកអ្នករីកចម្រើន។




USAID FROM THE AMERICAN PEOPLE

US-ASEANCONNECT partnering for sustainable, innovative, economic growth

US-ASEAN BUSINESS COUNCIL, INC.




# ASEAN SME Academy

ប្រឈមមុខជាមួយ**បញ្ហារបស់លោកអ្នក។** ធ្វើឲ្យសហគ្រាស**លោកអ្នករីកចម្រើន។**

ទោះបីជាក្រុមហ៊ុនលោកអ្នកទើបដំណើរការក្តី  កំពុងរីកចម្រើនក្តី ឬត្រៀមខ្លួននឹងនាំចេញក្តី ចូរអនុវត្តវិធីធ្វើឲ្យអាជីវកម្មរបស់លោកអ្នកឈានទៅមុខតាមរយៈវេទិការៀនសូត្រអនឡាញរបស់យើង។ បណ្ឌិត្យសភាអាស៊ានយើងផ្តល់ជូនវគ្គបណ្តុះបណ្តាលដោយឥតគិតថ្លៃ និងផ្តល់ជូនព័ត៏មាននានាអំពីប្រភពធនធានដើម្បីបំពេញសេចក្តីត្រូវការសហគ្រាសធុនតូច និងមធ្យម (SMEs) ដែលប្រតិបត្តិការនៅអាស៊ាន។

ASEAN SME Academy

## **ការគាំទ្រ**សហគ្រាសធុនតូច និងមធ្យមនៅសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍(អាស៊ាន)

សហគ្រាសធុនតូច និងមធ្យមដើរតួយ៉ាងសំខាន់នៅអាស៊ីអគ្នេយ៍។ សហគ្រាសធុនតូច និងមធ្យមមានជាង ៩៦៕ នៃសហគ្រាសទាំងអស់ និងបង្កើតការងារបាន ៥០ ទៅ ៩៥៕និងចូលរួមក្នុងផលិតផលក្នុងស្រុកសរុប(GDP)បាន ២៣ ទៅ ៥៨៕។

អាស៊ានប្តេជ្ញាចិត្តលើកកម្ពស់ការអភិវឌ្ឍន៍សហគ្រាសធុនតូច និងមធ្យមដើម្បីពង្រីកកំណើនកាត់បន្ថយភាពក្រីក្រ និងលើកតម្កើងសមធម៌។ ក្នុងន័យនេះ ការលើកកម្ពស់ភាពប្រកួតប្រជែង ស្ថិរភាព និងភាពធន់របស់សហគ្រាសធុនតូច និងមធ្យមមានសារៈសំខាន់ជាខ្លាំងដើម្បីធានាឲ្យមានការចូលរួមឲ្យកាន់តែច្រើនរបស់សហគ្រាសទាំងនេះទៅក្នុងកាលានុវត្តភាពសេដ្ឋកិច្ចផុសចេញពីសហគមន៍សេដ្ឋកិច្ចអាស៊ាន។

ប៉ុន្តែសហគ្រាសធុនតូច និងមធ្យមជាច្រើននៅតែជួបប្រទះនឹងបញ្ហាប្រឈមជាច្រើន រួមទាំងចំណេះដឹងមានកម្រិតអំពីរបៀបដំណើរការ និងការពង្រីកអាជីវកម្ម






បណ្ឌិត្យសភាអាស៊ានផ្តល់ជូននូវវគ្គបណ្តុះបណ្តាលជាសេរី និងធនធានដើម្បីជួយដល់សហគ្រាសធុនតូច និងមធ្យមនៅអាស៊ាន ដើម្បីលើកកម្ពស់សមត្ថភាពរបស់ខ្លួនដើម្បីទទួលបានហិរញ្ញប្បទាន, ប្រកួតប្រជែង ទីផ្សារក្នុងតំបន់ និងអន្តរជាតិ, ប្រើប្រាស់ព័ត៌មាន និងសេវាកម្មប្រឹក្សាយោបល់នានា, និងប្រើប្រាស់បច្ចេកវិទ្យា និងនវានុវត្តថ្មីៗដោយជំនាញ។

ឯកសារមេរៀនអនឡាញជួយគាំទ្រសហគ្រាសធុនតូច និងមធ្យមនៅបីកម្រិត៖ ពេលចាប់ផ្តើមអាជីវកម្ម, អាជីវកម្ម កំពុងលូតលាស់, និងអាជីវកម្មដែលត្រៀមនាំចេញ។ វគ្គបណ្តុះបណ្តាលដោយឥតគិតថ្លៃនេះអាចសិក្សាបានទៅតាមល្បឿនរបស់ខ្លួនឯងដែលអាចចាប់បាន និងត្រូវបានរៀបចំឡើងស្របតាមរបៀបរៀន និងវត្ថុបំណងផ្សេងៗគ្នា។ តារាងអ្នកផ្តល់សេវាធុរកិច្ចក្នុងចំណុច/ផ្នែកធនធាននានា ត្រូវបានរៀបចំតាមប្រទេសដើម្បីអាចភ្ជាប់ទំនាក់ទំនងទៅនឹងអ្នកផ្តល់សេវាធុរកិច្ចពាក់ព័ន្ធនានាសម្រាប់សហគ្រាសធុនតូច និងមធ្យម



# ធ្វើជាដៃគូជាមួយ
## ក្រុមហ៊ុនដែលល្បី

**បណ្ឌិត្យសភាអាស៊ាន ផ្ដល់ជូននូវឯកសារបណ្ដុះបណ្ដាលជាច្រើនពីក្រុមហ៊ុនជាសមាជិករបស់សម្ព័ន្ធធុរកិច្ចអាមេរិក-អាស៊ានដែលទទួលបានជោគជ័យចំនួន ៥០០ ក្រុមហ៊ុន ក៏ដូចជាភ្ជាប់ (links) ទៅព័ត៌មានធុរកិច្ចនៅអាស៊ានជាច្រើនទៀត។**

លើសពីនេះទៅទៀត បណ្ឌិត្យសភាអាស៊ានបានដាក់បញ្ចូលឯកសារបណ្ដុះបណ្ដាលជាច្រើនទៀតដោយផ្ដោតទៅលើសហគ្រាសធុនតូច និងមធ្យមពីបណ្ដាគ្រឹះស្ថាននានាទាំងក្នុងតំបន់ និងអន្តរជាតិ។ នេះមានន័យថា វគ្គបណ្ដុះបណ្ដាលរបស់យើងជាជម្រើសដ៏ល្អដែលត្រូវបានរៀបចំ កែសម្រួលតាមតម្រូវការ ពិសោធន៍ និងសាកល្បងដើម្បីជួយឱ្យលោកអ្នកអាចបង្កើនអាជីវកម្មរបស់ខ្លួនបាន។

បច្ចុប្បន្ននេះ ឯកសារវគ្គបណ្ដុះបណ្ដាលរបស់យើងមានការចូលរួមចំណែកពីក្រុមហ៊ុនធំៗដូចជា ក្រុមហ៊ុន Baker & McKenzie, Facebook, Google, HP, អង្គការ ILO, ក្រុមហ៊ុន Mastercard, Microsoft, Paypal, និង P&G.

# លក្ខណៈពិសេសរបស់បណ្ណិត្យសភាអាស៊ាន

តាមរយៈបណ្ណិត្យសភាអាស៊ានលោកអ្នកអាចទទួលបានអត្ថប្រយោជន៍ចំនួនបីយ៉ាងគឺ៖ **ការបណ្តុះ បណ្តាល, ធនធាន**, និងការចូលរួមព្រឹត្តិការណ៍នានា។



## ការបណ្តុះបណ្តាល

### មានវគ្គបណ្តុះបណ្តាលគ្រប់កម្រិតសម្រាប់សហគ្រាសធុនតូច និងមធ្យម។

**បណ្ណិត្យសភាអាស៊ានមានប្រធានបទបណ្តុះបណ្តាលជាច្រើនដែលអាចជួយ ឲ្យអាជីវកម្មរបស់លោកអ្នករីកចម្រើន មិនថាអាជីវកម្មរបស់អ្នកមានទំហំ ឬស្ថិតនៅដំណាក់កាលណាក៏ដោយ។**

ទោះបីជាអាជីវកម្មលោកអ្នកទើបតែចាប់ផ្តើម, កំពុងលូតលាស់, ឬត្រៀមខ្លួនរួចរាល់សម្រាប់នាំចេញក៏ដោយ ក៏សហគ្រាសនីមួយៗសុទ្ធតែមានឱកាស និងជម្រើសក្នុងការរៀនសូត្រពីបណ្ណិត្យសភាអាស៊ានផងដែរ។

## ធនធាន៖

### ជាអ្នកផ្តល់សេវាកម្មប្រកបដោយជំនាញដ៏ប៉ិនប្រសព្វនៅគ្រប់ប្រទេស

**នៅផ្នែកធនធាននៃបណ្ណិត្យសភាអាស៊ានមានបញ្ជីអ្នកផ្តល់សេវាកម្មរាប់រយពាសពេញរដ្ឋសមាជិកអាស៊ានទាំង ១០ ដែលអាចជួយ ឲ្យអាជីវកម្មរបស់លោកអ្នករីកចម្រើន។**

តាមរយៈបណ្ណិត្យសភាអាស៊ានលោកអ្នកអាចជ្រើសរើសប្រភេទសេវាកម្ម និងប្រទេសដែលលោកអ្នកត្រូវការ ហើយតារាង/បញ្ជីអ្នកផ្តល់សេវាកម្មផ្សេងៗដែលលោកអ្នកអាចចុះកិច្ចសន្យាដោយផ្ទាល់ដើម្បីជួយគាំទ្រអាជីវកម្មរបស់លោកអ្នក។

តំណភ្ជាប់ (links) ជាច្រើនមានសេវាកម្មពាក់ព័ន្ធនឹងម្ចាស់អាជីវកម្មជាស្ត្រី និង/ឬសហគ្រាសដែលប្រតិបត្តិការដោយស្ត្រី នឹងការលើកកម្ពស់សហគ្រិនភាពស្ត្រី។

ប្រធានបទ៖

- អ្នកផ្តល់សេវាកម្មហិរញ្ញវត្ថុ
- ការអភិវឌ្ឍន៍ធនធានមនុស្ស
- ការចាប់ចូលទីផ្សារ និងអន្តរជាតូបនីយកម្ម
- គោលនយោបាយ និងបទបញ្ញត្តិ
- ផលិតភាព, បច្ចេកវិទ្យា, និងនវានុវត្តន៍

## ព្រឹត្តិការណ៍នានា៖

### ការផ្សារភ្ជាប់សហគ្រាសធុនតូច និងមធ្យមអាស៊ាន

**ផ្នែកព្រឹត្តិការណ៍នានារបស់បណ្ណិត្យសភាយើងមានប្រាប់ពីកាលបរិច្ឆេទនៃព្រឹត្តិការណ៍នានាពាក់ព័ន្ធនឹងសហគ្រាសធុនតូច និងមធ្យមនៅក្នុងតំបន់។**

ចំណុចនេះរួមបញ្ចូលទាំងកិច្ចប្រជុំ, ឱកាសចូលរួមវគ្គបណ្តុះបណ្តាលនានា, និងសិក្ខាសាលាថ្មីៗដើម្បីជួយលោកអ្នកអភិវឌ្ឍ និងពង្រីកសហគ្រាសរបស់លោកអ្នក។ ប្រសិនបើលោកអ្នកមិនអាចចូលរួមព្រឹត្តិការណ៍ទាំងនោះទេ ឯកសារពាក់ព័ន្ធមានដូចជារបៀបវារៈ, បទបង្ហាញ, និងវីដេអូត្រូវបានគេដាក់ចូលក្នុងគេហទំព័របណ្ណិត្យសភាយើង។



# ចាប់ផ្តើមចូលរៀនវគ្គបណ្តុះបណ្តាល

ចាប់ផ្តើមពេលណាក៏បាន តាមល្បឿនដែលលោកអ្នកចាប់បាន ដោយមិនគិតថ្លៃ។

**www.asean-sme-academy.org**



ប្រភេទវគ្គដែលមាន



**១ ចុះឈ្មោះ**

ចាប់ផ្តើមដោយចុះឈ្មោះលោកអ្នកលើគេហទំព័រ។ លឿន ងាយ ស្រួល និងមិនត្រូវការផ្ទៀងផ្ទាត់ជាមួយសារអេឡិចត្រូនិកនោះទេ (email)។

ពេលចុះឈ្មោះរួចហើយ លោកអ្នកអាចរៀនវគ្គបណ្តុះបណ្តាលភ្លាម។

**២** ក្នុងវគ្គសិក្សានីមួយៗ លោកអ្នកនឹងឃើញមានការពិពណ៌នាសង្ខេប រួមទាំងអត្ថប្រយោជន៍ចំពោះអាជីវកម្មរបស់លោកអ្នក។

**ជ្រើសរើសវគ្គបណ្តុះបណ្តាល និងមេរៀនដែលលោកអ្នកចង់រៀន។**

នៅក្នុងប្រអប់ "បណ្តុះបណ្តាល" ('TRAINING') សមាជិកដែលចុះឈ្មោះហើយ អាចចូលរៀនមេរៀនដែលមានស្រាប់ទាំងអស់។ លោកអ្នកអាចជ្រើសរើសវគ្គសិក្សាទៅតាមប្រភេទ និងកម្រិតនៃវគ្គ។ លោកអ្នកក៏អាចចូលរៀនប្រភេទវគ្គសិក្សាដោយផ្ទាល់ពីទំព័រគោលដៅបន្ទាប់។

ក្នុងវគ្គសិក្សានីមួយៗ លោកអ្នកនឹងឃើញមានការពិពណ៌នាសង្ខេប រួមទាំងអត្ថប្រយោជន៍ចំពោះអាជីវកម្មរបស់លោកអ្នក។





**៣ រៀនវគ្គសិក្សា**

នៅពេលដែលលោកអ្នកបានសម្រេចចិត្តថា វគ្គសិក្សាណាដែលលោកអ្នកនឹងរៀន ហើយ សូមចុចលើប៊ូតុង "**រៀនវគ្គនេះ**" ('Take this course')។



ការពិព័ណ៌នានៃវគ្គបណ្តុះបណ្តាលក៏រួមបញ្ចូលពីចំនួនមេរៀននៅក្នុងវគ្គនោះផងដែរ។



វគ្គសិក្សាខ្លះមាន សំណួរសាកល្បងដើម្បីតេស្តការយល់នូវមេរៀនរបស់លោកអ្នក ហើយលោកអ្នកត្រូវតែទទួលពិន្ទុជាប់មុននឹងអាច រៀនបន្តទៀតបាន។





**ដាក់កំណត់សម្គាល់កម្មវិធី**

នៅក្នុងមេរៀននីមួយៗ លោកអ្នកអាចត្រួតពិនិត្យឡើងវិញមេរៀនដែលបានជ្រើសរើស។

បន្ទាប់ពីបានបញ្ចប់មេរៀន សូមកុំភ្លេចចុចលើប៊ូតុង "**សម្គាល់បញ្ចប់**" (**'Mark Complete'**) ដើម្បីបន្តទៅមេរៀនបន្ទាប់។

វគ្គសិក្សាដែលបានបញ្ចប់ នឹងត្រូវបានកត់សម្គាល់ជាពណ៌បៃតង ដូច្នេះលោកអ្នកអាចតាមដានមើលការរីកចម្រើនរបស់លោកអ្នកបាន។





សម្រាប់វគ្គមួយចំនួន លោកអ្នកនឹងត្រូវបានស្នើឲ្យចូលទៅកាន់គេហទំព័រមួយថ្មីទៀត។ សូមចុច "**ចូលរៀន**" (**'Enroll'**) និងអនុវត្តតាមការណែនាំនានាដើម្បីចូលរៀនបាន។

**៤** វគ្គមួយចំនួនមានប្រគល់វិញ្ញាបនបត្របញ្ចប់ការសិក្សាជូន។



**៥ តាមដានការរីកចម្រើនរបស់លោកអ្នក**

នៅក្នុងប្រអប់ម៉ាយប្រូហ្វាល (**'My Profile'**) លោកអ្នកអាចមើលឃើញវគ្គសិក្សាណាខ្លះដែលលោកអ្នកបានចូលរៀន។ វគ្គសិក្សាដែលលោកអ្នកបានរៀនចប់សព្វគ្រប់ទាំងអស់នឹងត្រូវបានបង្ហាញជាពណ៌បៃតង។



# រឿងរ៉ាវផ្សេងៗពីអ្នកសម្របសម្រួលបណ្ឌិត្យសភាអាស៊ាន និងសហគ្រាសធុនតូចបំផុត ធុនតូច និងមធ្យម

រហូតមកដល់បច្ចុប្បន្ន បណ្ឌិត្យសភាអាស៊ានបានបណ្តុះបណ្តាលបុគ្គលិកបានជាង **១៩០ នាក់មកពីស្ថាប័នជម្រុញធុរកិច្ចសហគ្រាសធុនតូច** និងមធ្យមដូចជាសមាគមន៍ពាណិជ្ជកម្ម និងសហគ្រិន, គ្រឹះស្ថានអប់រំ, អ្នកផ្តល់សេវាកម្មអភិវឌ្ឍន៍ធុរកិច្ច, គ្រឹះស្ថានឯកជន និងស្ថាប័នរដ្ឋដែលគាំទ្រការអភិវឌ្ឍន៍សហគ្រាសធុនតូច **និងមធ្យមនៅប្រទេសកម្ពុជា, ឥណ្ឌូនេស៊ី, ឡាវ, ម៉ាឡេស៊ី, ហ្វីលីពីន, ថៃ, និងវៀតណាម។**

ទាំងនេះគឺជារឿងរ៉ាវមួយចំនួនរបស់ពួកគាត់។



វីនស្តុន ធី ស៊ីងហ្គន់
ប្រធានការិយាល័យខេត្ត កាហ្គាយ៉ានអ្នកឯកទេសអភិវឌ្ឍន៍ពាណិជ្ជកម្ម និងឧស្សាហកម្ម, នៃនាយកដ្ឋានពាណិជ្ជកម្ម និងឧស្សាហកម្ម, ភូមិ ភាគ ២,

**ប្រទេសហ្វីលីពីន**

*«បណ្ឌិត្យសភាអាស៊ាន គឺជាជំនួយយ៉ាងច្រើនក្នុងការបង្កើតបរិយាកាសអំណោយផលសម្រាប់សហគ្រិនភាពសហគ្រាស តូចបំផុត ធុនតូច និងមធ្យម។ ជាមួយនឹងវគ្គបណ្តុះបណ្តាលរបស់ខ្លួន បណ្ឌិត្យសភានេះបានក្លាយទៅជាវេទិកាដ៏មានសារៈសំខាន់សម្រាប់ម្ចាស់អាជីវកម្មដើម្បីបង្កើនជំនាញអាជីវកម្មរបស់ខ្លួនបន្ថែមទៀត»*

ក្នុងនាមជាអ្នកសម្របសម្រួលនៅមជ្ឈមណ្ឌលផ្តល់សេវាកម្មពេញលេញឈ្មោះថា ណេហ្គោស៊ីយ៉ូ នេះជាក្តីសុបិនមួយក្នុងចំណោមក្តីសុបិននានារបស់លោក វីនស្តុន ដែលចង់ឃើញសហគ្រាស តូចបំផុត ធុនតូច និងមធ្យមអភិវឌ្ឍសមត្ថភាព ដើម្បីធ្វើឲ្យអាជីវកម្មរបស់គាត់រីកចម្រើន។ ជាមួយនឹងវគ្គបណ្តុះបណ្តាលអនឡាញជាច្រើនដែលជាពិសេសត្រូវបានរៀបចំឡើងសម្រាប់សហគ្រាសធុនតូច និងមធ្យម លោកវីនស្តុនមើលឃើញថា បណ្ឌិតសភាអាស៊ាន គឺជាវេទិកាមួយយ៉ាងសំខាន់ដើម្បីសម្រេចបាននូវគោលបំណងនេះ។

ដើម្បីបន្តជំរុញការចូលរៀន និងការប្រើប្រាស់បណ្ឌិតសភាអាស៊ាននេះ លោកវីនស្តុនបានជួយរៀបចំជាវគ្គបណ្តុះបណ្តាលគ្រូបង្គោលសម្រាប់អ្នកសម្របសម្រួលមជ្ឈមណ្ឌលណេហ្គោស៊ីយ៉ូនិង មន្ត្រីពាណិជ្ជកម្ម និងឧស្សាហកម្មក្រុង, នាយកដ្ឋានពាណិជ្ជកម្ម និងឧស្សាហកម្ម, ភូមិភាគ ២។

វគ្គបណ្តុះបណ្តាលចំនួនពីរដំបូង គឺសម្រាប់គ្រឹះស្ថាននានាដែលគាំទ្រសហគ្រិនជាស្ត្រីដោយមានអ្នកចូលរួមមកពីកម្មវិធីជំនួយជីវភាព, សមាគមន៍ប៉ារ៉ូលូណាន់ដែលជាអង្គការរបស់អតីតពលករចំណាកស្រុកទៅក្រៅប្រទេស។



វគ្គបណ្ដុះបណ្ដាលចុងក្រោយគេគឺធ្វើឡើងនៅក្នុងខែកុម្ភៈ ឆ្នាំ ២០១៧ ដោយមានការចូលរួមពីអ្នកប្រឹក្សាធុរកិច្ច និងគ្រូបង្គោលសហគ្រាសធុនតូច និងមធ្យមតំណាងឲ្យខេត្តទាំង ៥ នៃភូមិភាគជ្រលងភ្នំកាហ្គាយ៉ានចំនួន ៥២ នាក់។ ក្នុងរយៈពេលពីរថ្ងៃដែលពួកគេប្រមូលផ្តុំគ្នាចែករំលែកបទពិសោធន៍ និងបញ្ហាប្រឈមដែលគេមានក្នុងការគាំទ្រសហគ្រាសធុនតូច និងមធ្យម និងរៀនអំពីរបៀបប្រើប្រាស់បណ្ឌិត្យសភាអាស៊ាន។

ដើម្បីពង្រីកផលគុណលទ្ធផលនៃវគ្គបណ្ដុះបណ្ដាល សិក្ខាកាមបានប្ដេជ្ញាចិត្តរៀបចំវគ្គបណ្ដុះបណ្ដាលជូនសហគ្រាសធុនតូចបំផុត ធុនតូច និងមធ្យមនៅក្នុងបណ្ដាញរបស់ពួកគេ។ ក្នុងចំណោមវគ្គផ្សេងៗសិក្ខាកាមយល់ឃើញថាវគ្គបណ្ដុះបណ្ដាលសហគ្រិនឲ្យចេះមានមហិច្ឆតាដែលជាផ្នែកមួយនៃចង្កោមឧបករណ៍អភិវឌ្ឍន៍សហគ្រាសតាមសហគមន៍ពីបណ្ឌិត្យសភាអាស៊ានមានអត្ថប្រយោជន៍ជាពិសេស។

លោកវីស្តុន  គិតថាវគ្គនេះសក្តិសមចំពោះការបង្រៀនអាជីវកម្មនៅតាមមូលដ្ឋាន  និងសហគ្រិននៅក្នុងវិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធអំពីសហគ្រិនភាព។ ក្រៅពីនេះ លោកណែនាំឲ្យអ្នកដែលទើបចាប់ផ្តើមអាជីវកម្មឬអាជីវកម្មដែលនៅមិនទាន់រលូនរៀនវគ្គបណ្ដុះបណ្ដាលម្ចាស់អាជីវកម្មខ្នាតតូចសម្រាប់ ។





**ជីណូវីវ៉ា ជី. អានជេតា**

អ្នកឯកទេសអភិវឌ្ឍន៍ពាណិជ្ជកម្ម និងឧស្សាហកម្មជាន់ ខ្ពស់នៃ,មជ្ឈមណ្ឌលបណ្ដុះបណ្ដាលពាណិជ្ជកម្មហ្វីលីពីន (PTTC)។

ប្រទេសហ្វីលីពីន

*"ជាមួយបរិក្ខារបណ្ដុះបណ្ដាលទើបអភិវឌ្ឍន៍ថ្មីសម្រាប់អ្នកទើបចាប់ផ្តើមអាជីវកម្មដំបូង ខ្ញុំគិតថាបណ្ឌិត្យសភាអាស៊ានអាចបំពេញបន្ថែមមជ្ឈមណ្ឌលរបស់យើងជាមួយនឹងជំនាញ និងព័ត៌មានបន្ថែមដើម្បីជួយដល់សហគ្រាស តូចបំផុត ធុនតូច និងមធ្យមប្រតិបត្តិតាម ឬអភិវឌ្ឍអាជីវកម្មរបស់ពួកគេ។*

អ្នកនាងអ៊ីវ៉ា មានបទពិសោធន៍ជាច្រើនឆ្នាំធ្វើការងារជាមួយសហគ្រាសធុនតូច និងមធ្យមនៅប្រទេសហ្វីលីពីន។ ការធ្វើការងារនៅមជ្ឈមណ្ឌលបណ្ដុះបណ្ដាលពាណិជ្ជកម្មហ្វីលីពីន អ្នកនាងបានជួយសហគ្រិនឱ្យលូតលាស់ និងអភិវឌ្ឍអាជីវកម្មរបស់ពួកគេតាមរយៈការទទួលបានការបណ្ដុះបណ្ដាលសម្បូរបែប, សេវាកម្មអភិវឌ្ឍន៍ធុរកិច្ច,ព្រឹត្តិការណ៍ពាណិជ្ជកម្ម, និងសន្និសិទជាច្រើនពីមជ្ឈមណ្ឌលរបស់នាង។

ដោយសារតែមានការប្រើប្រាស់សេវាអ៊ីនធើណិត និងបដិវត្តិន៍បច្ចេកវិទ្យាយ៉ាងឆាប់រហ័ស  អ្នកនាងអ៊ីវ៉ាផ្តោតការងាររបស់នាងភាគច្រើនទៅលើការពង្រឹងសមត្ថភាពសហគ្រាសធុនតូចនិងមធ្យមក្នុងការប្រើប្រាស់ ពាណិជ្ជកម្មអេឡិចត្រូនិក (E-Commerce) ដែលជាកម្មវិធីដ៏ល្អបំផុតក្នុងចំណោមកម្មវិធីបណ្ដុះបណ្ដាលទូទៅរបស់អ្នកនាង។

នៅក្នុងឆ្នាំ ២០១៦ មជ្ឈមណ្ឌលបណ្ដុះបណ្ដាលពាណិជ្ជកម្មហ្វីលីពីនបានរៀបចំវគ្គបណ្ដុះបណ្ដាលសម្រាប់គ្រូបង្គោលដោយផ្តោតលើវិធីពង្រឹងអំណាចស្ត្រីឲ្យប្រើប្រាស់អ៊ី-ពាណិជ្ជកម្មប្រកបដោយប្រសិទ្ធភាព។






អ៊ី-ពាណិជ្ជកម្មផ្តល់នូវអត្ថប្រយោជន៍យ៉ាងសម្បើមដល់ស្ត្រីពីព្រោះវាចំណាយដើមទុននិងប្រតិបត្តិដើមដំបូងតិច និងអនុញ្ញាតឲ្យស្ត្រីគ្រប់គ្រងពេលវេលារបស់ពួកគេមានភាពបត់បែនជាងមុនប្រៀបធៀបនឹងអាជីវកម្មធម្មតា។

នៅក្នុងវគ្គបណ្តុះបណ្តាល ស្ត្រីចំនួន ១៥ នាក់ទទួលបានការបណ្តុះបណ្តាលអំពីមូលដ្ឋានគ្រឹះនៃពាណិជ្ជកម្មអេឡិចត្រូនិចដើម្បីដាក់អាជីវកម្មពួកគេតាមអនឡាញ។ វគ្គនេះរួមបញ្ចូលទាំងសិក្ខាសាលាអនុវត្តផ្ទាល់ពីអ្នកមានបទពិសោធន៍អំពីពាណិជ្ជកម្មអេឡិចត្រូនិចស្តីពីការប្រើប្រាស់ទំព័រហ្វេនរបស់ហ្វេសប៊ុក និងហ្វូកហ្គលធ្វើជាវិធីសម្រាប់សហគ្រាសធុនតូចបំផុត ធុនតូច និងមធ្យមចាប់ផ្តើមវត្តមានតាមអនឡាញរបស់ពួកគេ។ នៅថ្ងៃបន្ទាប់អ្នកចូលរួមបានចូលទៅសិក្សាមេរៀនពាក់ព័ន្ធពីវគ្គអនឡាញជាច្រើនទៀតរួមទាំងម៉ូឌុលរបស់បណ្ឌិត្យសភាស្តីពីការលក់តាមអនឡាញ, ការធ្វើទីផ្សារតាមបណ្តាញសង្គម, និងការពង្រឹងវត្តមាននៅលើសាកលលោកតាមរយៈការធ្វើទីផ្សារអនឡាញ។ បន្ទាប់មកទៀត អ្នកចូលរួមមានឱកាសពិភាក្សាគ្នាអំពីបញ្ហាប្រឈមនានានៃការចាប់ផ្តើមអាជីវកម្មជាមួយអ្នកអនុវត្តន៍ពាណិជ្ជកម្មអេឡិចត្រូនិច។

ជាទូទៅ វគ្គបណ្តុះបណ្តាលបញ្ហាជាច្រើនដូចជាមូលដ្ឋានគ្រឹះនៃពាណិជ្ជកម្មអេឡិចត្រូនិចនិងការធ្វើទីផ្សារឌីជីថលសម្រាប់សហគ្រាសធុនតូច និងមធ្យម ក្នុងពេលជាមួយគ្នានោះក៏បានបំពាក់ដល់សិក្ខាកាមនូវជំនាញព័ត៌មានវិទ្យាផងដែរដើម្បីជម្រុញឲ្យពួកគាត់ចេះទាញយកអត្ថប្រយោជន៍ពីពាណិជ្ជកម្មអេឡិចត្រូនិចដោយខ្លួនឯង។ ជាការជម្រុញបន្ថែមទៀត មជ្ឈមណ្ឌលបណ្តុះបណ្តាលពាណិជ្ជកម្មហ្វីលីពីនបានបន្តផ្សារភ្ជាប់សិក្ខាកាមជាមួយនឹងគ្រឹះស្ថានផ្សេងៗដែលអាចផ្តល់កិច្ចគាំទ្របន្ថែមទៀតដល់ពួកគាត់ដូចជាសម្ភារៈកុំព្យូទ័រ និងថវិកា។



## ទូច សុជាតា

នាយកគ្រប់គ្រងក្រុមហ៊ុនអ៊ីនស្លាយអ៊ីដ អ៊ីង និង ជាអនុប្រធានគណកម្មាធិការកសាងសមត្ថភាពសម្រាប់សមាគមន៍សហគ្រិនស្ត្រីកម្ពុជា (CWEA)

**ប្រទេសកម្ពុជា**

*"ខ្ញុំជឿជាក់យ៉ាងមុតមាំថាបណ្ឌិត្យសភាអាស៊ានពិតជាបានផ្តល់អត្ថប្រយោជន៍ជាច្រើនដល់សហគ្រិន។ បណ្ឌិត្យសភាអាស៊ានអាចពង្រីកចំណេះដឹង និងជំនាញរបស់ពួកគេអំពីវិធីអភិវឌ្ឍអាជីវកម្មរបស់ពួកគេ និងជួយឲ្យពួកគេចេះកសាងបណ្តាញតាមវិស័យ និងប្រទេសក្នុងតំបន់។*

សមាគមន៍សហគ្រិនស្ត្រីកម្ពុជា គឺជាកិច្ចផ្តួចផ្តើមរបស់ក្រសួងកិច្ចការនារីនៅកម្ពុជាដោយមានបេសកកម្មដើម្បីលើកទឹកចិត្ត និងគាំទ្រកំណើនស្ត្រីក្នុងធុរកិច្ចនៅកម្ពុជា។ ដើម្បីជួយស្ត្រីអាចចាប់ផ្តើម និងពង្រីកអាជីវកម្មរបស់ពួកគាត់ សមាគមន៍បានឲ្យអ្នកនាងសុជាតាចូលរួមវគ្គបណ្តុះបណ្តាលអ្នកសម្របសម្រួលបណ្ឌិត្យសភាអាស៊ាន។ ប្រការនេះអនុញ្ញាតឲ្យសុជាតាប្រើប្រាស់វគ្គបណ្តុះបណ្តាលរបស់បណ្ឌិត្យសភាអាស៊ានធ្វើជាផ្នែកមួយនៃកម្មវិធីបណ្តុះបណ្តាលរបស់សមាគមន៍សហគ្រិនស្ត្រីកម្ពុជាសម្រាប់សហគ្រិនជាស្ត្រី។

ចាប់តាំងពីបានទទួលការបណ្តុះបណ្តាលក្នុងឆ្នាំ ២០១៦ មក អ្នកនាងសុជាតាបានចែករំលែកចំណេះដឹងរបស់នាងជាមួយនឹងក្រុមផ្សេងៗចំនួនបីសមាជិកទាំង ២០ របស់សមាគមន៍នៅភ្នំពេញ, សហគ្រិនស្ត្រីចំនួន ២៥ នាក់នៅសៀមរាប, និងនិស្សិតសាកលវិទ្យាឯកទេសគ្រប់គ្រងធុរកិច្ចចំនួន ១៥ នាក់នៅរាជធានីភ្នំពេញ។






ភាគច្រើននៃអ្នកចូលរួមសុទ្ធតែជាសហគ្រិនធុនតូចបំផុត និងជាស្ត្រីក្នុងវិស័យសេវាកម្ម។ វគ្គសិក្សាដែលអ្នកនាងចូលចិត្តជាងគេ គឺវគ្គធ្វើទីផ្សារតាមបណ្តាញសង្គមពីព្រោះវាបានជម្រុញឲ្យអ្នកចូលរួមអនុវត្តដោយផ្ទាល់នូវអ្វីដែលបានរៀនទៅក្នុងអាជីវកម្មរបស់ពួកគាត់។

ក្រៅពីការបង្ហាញមេរៀនបណ្តុះបណ្តាលរបស់បណ្ឌិត្យសភាអាស៊ាន អ្នកនាងសុជាតា បានដាក់បញ្ចូលវគ្គប្រមូលគំនិត និងវគ្គពិភាក្សាទៅក្នុងការបណ្តុះបណ្តាលផងដែរ។ អ្នកនាងបានសុំឲ្យអ្នកចូលរួមចែករំលែកបទពិសោធន៍ និងបញ្ហាប្រឈមនានាក្នុងនាមជាសហគ្រិន ដើម្បីឲ្យពួកគាត់បានរៀនសូត្រពីគ្នាទៅវិញទៅមក។ អ្នកនាងក៏ណែនាំឲ្យមានការពិក្សាដោយប្រើចំណេះ និងជំនាញក្នុងនាមខ្លួនជាទីប្រឹក្សាធុរកិច្ច និងគ្រូបង្វឹក។

សម្រាប់សុជាតា បណ្ឌិត្យសភាអាស៊ាន គឺជាឧបករណ៍មួយយ៉ាងសំខាន់ក្នុងការធ្វើឲ្យប្រសើរឡើងនូវសមត្ថភាពរបស់សហគ្រាសធុនតូចបំផុត ធុនតូច និងមធ្យមដែលចេញមកពីការពិភាក្សាបន្តបន្ទាប់ទៀតជាមួយសិក្ខាកាម។ ជាក់ស្តែង ស្ត្រីម្ចាស់អាជីវកម្មម្នាក់នៅសៀមរាបបានប្រាប់សុជាតាថាបន្ទាប់ពីចូលរួមវគ្គបណ្តុះបណ្តាល គាត់ចេះប្រើហ្វេសប៊ុកដើម្បីបង្កើនការលក់របស់ខ្លួន។



## សារ៉ុន ស៊ី. សូរីយ៉ាណូ

អ្នកនាងគឺជាប្រធានសមាគមន៍ពលករចំណាកស្រុកហ្វីលីពីនប៉ារូលូរណាន់

**ប្រទេសហ្វីលីពីន**

*"វគ្គបណ្តុះបណ្តាលមានអត្ថប្រយោជន៍ជាខ្លាំង។ ខ្ញុំចង់រៀនបន្ថែមទៀតពីព្រោះវគ្គទាំងនេះអាចជួយខ្ញុំឲ្យចេះធ្វើជំនួញ"*

អ្នកនាងសារ៉ុន គឺជាសិក្ខាកាមម្នាក់ក្នុងចំណោមសិក្ខកាមដែលទទួលការបណ្តុះបណ្តាលរៀបចំឡើងដោយនាយកដ្ឋានពាណិជ្ជកម្មនិងឧស្សាហកម្ម, ការិយាល័យខេត្តកាហ្គាយ៉ាន ភូមិភាគ ២ ។ វគ្គបណ្តុះបណ្តាលផ្តោតលើការបង្កើតសហគ្រិនដែលមានមហិច្ឆតាក្នុងវគ្គនោះសិក្ខាកាមរៀនផ្តោតលើការបង្កើនសមត្ថភាពខ្លួនដើម្បីផ្តើមអាជីវកម្មដូចជាការត្រួតពិនិត្យឡើងវិញអំពីគោលការណ៍ធុរកិច្ចមូលដ្ឋានសម្រាប់ផលិតផល, ទីកន្លែង, ការផ្សព្វផ្សាយ, តម្លៃ, ការវាយតម្លៃគំនិតអាជីវកម្ម, និងការអភិវឌ្ឍន៍យុទ្ធសាស្ត្រធុរកិច្ច។

ជាមួយនឹងសហការីដែលជាអតីតពលករចំណាកស្រុកចំនួន៥០ នាក់ទៀត អ្នកនាងសារ៉ុនបានរៀនអំពីរបៀបចាប់ផ្តើមអាជីវកម្មកែច្នៃសាច់ និងធ្វើនំ។ ពួកគាត់រៀនមួយជំហានម្តងៗអំពីរបៀបធ្វើអាជីវកម្ម, អភិវឌ្ឍអាជីវកម្ម, ហើយបន្ទាប់មកផ្សព្វផ្សាយផលិតផលរបស់ពួកគាត់។ ដោយសារវគ្គបណ្តុះបណ្តាលនេះមានលក្ខណៈអនុវត្តដោយផ្ទាល់ គាត់អាចស្វែងយល់វគ្គដោយងាយស្រួល និងចាប់ផ្តើមអាជីវកម្មរបស់គាត់តែម្តង។

បន្ទាប់ពីវគ្គបណ្តុះបណ្តាល អ្នកនាងសារ៉ុន និងសហការីម្នាក់ៗទទួលបាន ១០,០០០ប៉េសូ ពីកម្មវិធីជំនួយរៀបចំឡើងសម្រាប់ជួយពលករចំណាកស្រុកពេលត្រលប់មកវិញឲ្យគាត់អាចចាប់ផ្តើមអាជីវកម្មមួយខ្លួនឯង។ នាយកដ្ឋានពាណិជ្ជកម្មនិងឧស្សាហកម្មនិងមជ្ឈមណ្ឌលណែហ្គោស៊ីយ៉ូបានជួយរៀចំឯកសារ និងដំណើរការនានាដើម្បីទទួលជំនួយនេះ។ អ្នកនាងសារ៉ុន ប្រើប្រាស់ជំនួយជាទុនបឋមដើម្បីចាប់ផ្តើមអាជីវកម្មកែច្នៃសាច់របស់គាត់។



## ជេស៊ីកា អ៊ីម. អាបៀរ

ជាអ្នកឯកទេសជាន់ខ្ពស់អភិវឌ្ឍន៍ពាណិជ្ជកម្ម និងឧស្សាហកម្ម នាយក ដ្ឋានពាណិជ្ជកម្ម និង ឧស្សាហកម្មភូមិភាគទី១០ ការិយាល័យខេត្ត មីនដាណាវភាគខាងជើង

**ប្រទេសហ្វីលីពីន**

*«បណ្ឌិត្យសភាអាស៊ានផ្តល់ឲ្យសហគ្រិននូវឱកាសរៀនសូត្រដោយខ្លួនឯង និងតាមល្បឿនដែលខ្លួនចាប់បាន។ ប្រការនេះអនុញ្ញាតឲ្យសិក្ខាកាមរៀបចំពេលវេលាសម្រាប់រៀន និងធ្វើអាជីវកម្មបានល្អ»*

ក្នុងនាមជាអ្នកសម្របសម្រួលខេត្តសម្រាប់មជ្ឈមណ្ឌលណេហ្គោស៊ីយ៉ូអ្នកនាងជេស៊ីកំពុងតែស្វែងរកឧបករណ៍ និងវិធីសាស្ត្រដើម្បីធ្វើឲ្យប្រសើរឡើងនូវសមត្ថភាពរបស់សហគ្រាសធុនតូចបំផុត ធុនតូច និងមធ្យមក្នុងតំបន់របស់នាង។ សេវាកម្មមួយចំនួនដែលអ្នកនាងផ្តល់ជូនរួមមាន៖ ព័ត៌មានអាជីវកម្ម និងការគាំទ្រដោះស្រាយបញ្ហាច្បាប់ និងរដ្ឋបាល។ បន្ថែមលើនេះ អ្នកនាងក៏សម្របសម្រួលឲ្យមានវគ្គបណ្តុះបណ្តាល និងសិក្ខាសាលាធុរកិច្ចពាក់ព័ន្ធនឹងសហគ្រិនភាពផងដែរ។

អ្នកនាងជេស៊ី យល់ឃើញថាបណ្ឌិត្យសភាអាស៊ានមានសារសំខាន់ណាស់ក្នុងការគាំទ្រសហគ្រាសធុនតូចបំផុត ធុនតូច និងមធ្យម។ នៅក្នុងខែមីនា ឆ្នាំ ២០១៧ អ្នកនាងជេស៊ីបានបណ្តុះបណ្តាលសហគ្រិនចំនួន ១៥ រូបដែលមានអាជីវកម្មផ្សេងៗគ្នា មកពីវិស័យសេវាកម្ម និងឧស្សាហកម្មដើម្បីឲ្យគាត់ចូលរៀនវគ្គនៅក្នុងបណ្ឌិត្យសភាអាស៊ាន។

វគ្គ ពាណិជ្ជកម្មអេឡិចត្រូនិច គឺជាវគ្គមួយក្នុងចំណោមវគ្គដែលអ្នកនាងចូលចិត្តជាងគេពីព្រោះសិក្ខាកាមអាចរៀនបានងាយស្រួលពីវិធីប្រើប្រាស់បណ្តាញសង្គមដើម្បីផ្សព្វផ្សាយផលិតផលរបស់ខ្លួន។ ក្នុងអំឡុងពេលនៃវគ្គបណ្តុះបណ្តាលអ្នកនាងជេស៊ីផ្តល់យោបល់ឲ្យសិក្ខាកាមអនុវត្តមេរៀនដោយចាប់ផ្តើមលក់ផលិតផលរបស់ខ្លួនលើហ្វេសប៊ុកពីព្រោះវាមិនអស់ប្រាក់ និងមានអត្ថប្រយោជន៍ជាច្រើនទៀត។ បញ្ហាប្រឈមមួយដែលអ្នកនាងជួបនោះ គឺល្បឿនអ៊ីនធើណិតយឺតដែលធ្វើឲ្យការបណ្តុះបណ្តាលមានការលំបាក។





## លោក លី ហ៊ុយ

ជានាយកក្រុមហ៊ុនសំណង់ និងតុបតែងផ្ទៃខាងក្នុង SARW និងជានាយកអង្គការ វ៉ែន ធូ វ៉ែន ខេមបូឌា

**ប្រទេសកម្ពុជា**

*«ខ្ញុំរីករាយណាស់ដែលយើងអាចស្វែងរកប្រធានបទសិក្សាក្នុងបណ្ឌិត្យសភាអាស៊ាននេះ ទើបយើងអាចជ្រើសរើសវគ្គដែលពាក់ព័ន្ធសំខាន់»*

ចាប់តាំងពីបានទទួលការបណ្តុះបណ្តាល និងប្រើប្រាស់បណ្ឌិត្យសភាអាស៊ានក្នុងឆ្នាំ២០១៦ មក លោក លី ហ៊ុយបានចែករំលែកចំណេះដឹងជាមួយបណ្តាញរបស់គាត់។គាត់គឺជាប្រធាន SARW ជាក្រុមហ៊ុនសំណង់ និងជាប្រធានអង្គការវ៉ែន ធូ វ៉ែន ជាអង្គការសប្បុរសធម៌ជួយដល់សិស្សនិស្សិតក្រីក្រនៅកម្ពុជាដែលមានគោលបំណងរៀននៅសាកលវិទ្យាល័យ។

លោក លី ហ៊ុយ មានក្តីរំភើបជាមួយនឹងមុខងារផ្សេងៗរបស់បណ្ឌិត្យសភាអាស៊ានដែលធ្វើឲ្យគាត់ស្វែងរកប្រធានបទជាក់លាក់ណាមួយដើម្បីអភិវឌ្ឍអាជីវកម្មសក្តិសមទៅនឹងសេចក្តីត្រូវការរបស់គាត់។ ធ្វើដូច្នេះ គាត់អាចរៀនវគ្គណាមួយ ហើយរៀនតាមខ្លឹមវគ្គនោះតាមល្បឿនមួយដែលគាត់អាចចាប់បាន។

លោក លី ហ៊ុយ ក៏ជឿជាក់ថាវគ្គសិក្សារបស់បណ្ឌិត្យសភាអាស៊ានអាចជួយសិស្សនិស្សិតរបស់ វ៉ែន ធូ វ៉ែន ត្រៀមខ្លួនចាប់ផ្តើមបង្កើតសហគ្រាសធុនតូចបំផុតដើម្បីផ្តល់នូវការថែទាំធ្មេញ និងថែទាំវេជ្ជសាស្ត្រសាធារណៈបន្ទាប់ពីបានរៀនចប់។ ជាការគាំទ្រដល់ជំនឿជាក់របស់គាត់ គាត់បានបណ្តុះបណ្តាលសិស្សនិស្សិតចំនួន២០ នាក់ឲ្យចេះប្រើប្រាស់បណ្ឌិត្យសភាអាស៊ាន។

ក្នុងនាមជានាយកក្រុមហ៊ុន SARW មានអាជីវកម្មសំណង់ និងតុបតែង លោកបានណែនាំប្រធានផ្នែកនានាឲ្យទៅរៀនតាមអនឡាញអំពីការធ្វើទីផ្សារ, រៀបចំផែនការធុរកិច្ច, និងការទទួលអត្ថប្រយោជន៍ពីបណ្តាញព័ត៌មានសង្គម។

បន្ទាប់ពីបានរៀនវគ្គ រុញអាជីវកម្មលោកអ្នកទៅមុខជាមួយនឹងហ្វេសប៊ុក ក្រុមការងាររបស់គាត់បច្ចុប្បន្នបានដំណើរការ ការធ្វើទីផ្សារតាមបណ្តាញសង្គមរបស់ក្រុមហ៊ុនប្រកបដោយប្រសិទ្ធភាពជាងមុនដោយបានប្រើប្រាស់គ្រប់មុខងាររបស់ហ្វេសប៊ុកដើម្បីពង្រីកទីផ្សារគោលដៅរបស់ពួកគេ។

លើសពីនេះ ផ្នែកធនធានមនុស្សក្រុមហ៊ុនរបស់គាត់បានលើកទឹកចិត្តឲ្យបុគ្គលិកឲ្យរៀនវគ្គអនឡាញដើម្បីអភិវឌ្ឍជំនាញរបស់ពួកគេ។ ថ្មីៗនេះ បុគ្គលិកទទួលការលើកទឹកចិត្តឲ្យចូលរៀនវគ្គបណ្តុះបណ្តាលពីបណ្ឌិត្យសភាអាស៊ានស្តីពីការគ្រប់គ្រងសារពើភ័ណ្ឌ និងលំហូរសាច់ប្រាក់។



## ម៉ាស៊ីហ្វ

ទីប្រឹក្សាបច្ចេកវិទ្យាព័ត៌មាន នៅមជ្ឈមណ្ឌលសេវាកម្មធុរកិច្ចរួម (PLUT) សម្រាប់សហករ និងសហគ្រាសធុនតូចបំផុត ធុនតូច និងមធ្យម នៅ នូសា តេងហ្គារ៉ាខាងលិច (KUMKM)

**ប្រទេសឥណ្ឌូនេស៊ី**

*"មុខងារវិវត្តិទៅមុខរបស់វគ្គគឺអស្ចារ្យ ពីព្រោះគ្រប់ពេលវេលាដែលយើងរៀនចប់វគ្គ មានកំណត់ពណ៌បៃតងបញ្ជាក់ប្រាប់ថាបានរៀនចប់។ បន្ថែមលើនេះ ខ្លឹមសារវគ្គផ្សេងៗរបស់បណ្ឌិត្យសភាអាស៊ានគឺល្អ! កម្រណាស់ដែលក្រុមហ៊ុននានាផ្តល់វគ្គល្អៗបែបនេះ"*

ជាមួយសាវតាព័ត៌មានវិទ្យារបស់គាត់ លោកម៉ាស៊ីហ្វមានគោលបំណងយូរមកហើយគឺចង់ជួយអាជីវកម្មធុនតូចនៅមូលដ្ឋានខេត្តឡំបុក របស់គាត់ឲ្យក្លាយជាមានបច្ចេកវិទ្យាខ្ពស់ឆ្លើយតបទៅនឹងបញ្ហាហិរញ្ញវត្ថុដែលពួកគេប្រឈម។ នៅពេលគាត់បានចូលរួមវគ្គបណ្តុះបណ្តាលអ្នកសម្របសម្រួលស្តីពីបណ្ឌិត្យសភាអាស៊ាននៅទីក្រុងហ្សាការតា ខែតុលា ឆ្នាំ២០១៦ នោះ លោកម៉ាស៊ីហ្វ បានចូលរួមជាមួយ សេនត្រាយូខេអឹម ដែលជាមជ្ឈមណ្ឌលផ្តល់សេវាកម្មធុរកិច្ចរួមនៅមូលដ្ឋានរួចទៅហើយ។ នេះគឺជាកម្មវិធីមួយស្ថិតក្រោមក្រសួងសហករ និងធុរកិច្ចខ្នាតតូច ដែលបានសេវាកម្មជាកញ្ចប់រួមមិនមែនហិរញ្ញវត្ថុទៅដល់អាជីវកម្មសហគ្រាសធុនតូចបំផុត ធុនតូច និងមធ្យម និងជួយសហគ្រាសទាំងនោះឲ្យចេះធ្វើទីផ្សារមានប្រសិទ្ធិភាពជាងមុន, បង្កើនផលិតភាព, និងធ្វើឲ្យប្រសើរឡើងនូវលទ្ធភាពទទួលបានហិរញ្ញវត្ថុ។

លោកម៉ាស៊ីហ្វ ពេញចិត្តនឹងតួនាទីជាអ្នកសម្របសម្រួល និងរីករាយនឹងការងារជាមួយភូមិជាច្រើននៅខេត្តឡំបុក ដែលជាធម្មតាគេធ្លាប់តែស្គាល់ថាជាខេត្តមួយផលិតតែផលិតផលចំណីអាហារ និងសិប្បកម្ម ឬផលិតផលជនជាតិដើមភាគតិចប៉ុណ្ណោះ។ ភ្លាមៗនោះ គាត់បានក្លាយជាអ្នកជ្រោមជ្រែងបង្កើត កំពង់ យូខេអឹម ឌីជីថលចំនួនប្រាំមួយ មានន័យថាជា ភូមិសហគ្រាសឌីជីថលធុនតូច និងមធ្យមសម្រាប់វិស័យទាំងប្រាំមួយរួមមានស៊ុតប្រៃ, ផ្សារសិល្បៈ, ក្រណាត់ត្បាញ, គ្រាប់គុជ, ឬស្សី, និងសំបកដូង។ ភូមិសហគ្រាសឌីជីថលធុនតូច និងមធ្យមគឺជាមជ្ឈមណ្ឌលសិក្សាចេញពីកម្មវិធីភាពជាដៃគូរវាងក្រុមហ៊ុនតែលកុម ដែលជាក្រុមហ៊ុនទូរគមនាគមន៍ដ៏ធំបំផុតរបស់ឥណ្ឌូនេស៊ី ជាមួយនឹងក្រសួងសហករ និងធុរកិច្ចខ្នាតតូច។ ភូមិសហគ្រាសឌីជីថលធុនតូច និងមធ្យមគឺដូចជាហាងទំនិញតែមួយសម្រាប់អាជីវកម្មតូចៗទាំងអស់ដែលជម្រុញឲ្យសិល្បៈករ និងសហគមន៍ផលិតយ៉ាងច្រើននៅក្នុងវិស័យ





ទទួលបានព័ត៌មានផ្សេង, ព័ត៌មានទីផ្សារផលិតផលរបស់ពួកគេតាមអនឡាញ, និងផ្សាភ្ជាប់ភូមិនានាតាមប្រព័ន្ធឌីជីថលដើម្បីឲ្យពួកគាត់បង្កើនអាជីវកម្មរបស់ខ្លួនកាន់តែខ្លាំងឡើង។

លោកម៉ាស៊ីហ្វ ជឿជាក់ថាបណ្ឌិត្យសភាអាស៊ានគឺជាប្រភពចំណេះដឹងដ៏មានតម្លៃដែលសហគមន៍ប្រើប្រាស់យ៉ាងច្រើននៅភូមិសហគ្រាសឌីជីថលធុនតូច និងមធ្យម។ គាត់ក៏បានសម្តែងការភ្ញាក់ផ្អើលដែលក្រុមហ៊ុនធំៗនាំមុខគេលើពិភពលោកដូចជា Google, HP Life, Microsoft, និង P&G មានចេតនាចែករំលែកចំណេះដឹងពួកគេតាមរយៈបណ្ឌិត្យសភាអាស៊ាននេះសោះ។ លោកម៉ាស៊ីហ្វក៏មានក្តីរំភើបផងដែរដែលសហគមន៍នានាដែលមកភូមិឌីជីថលអាចរៀនដោយផ្ទាល់ពីជំនាញផ្សេងៗរបស់ក្រុមហ៊ុនយក្សក្នុងវគ្គបណ្តុះបណ្តាលបណ្ឌិត្យសភាអាស៊ាន។

ជាមួយនឹងការបណ្តុះបណ្តាលអំពីបណ្ឌិត្យសភាអាស៊ានដែលគាត់ទទួលបាននៅក្រុងហ្សាការតាលោកម៉ាស៊ីហ្វក្លាយជាមានទំនុកចិត្តកាន់តែខ្លាំងថែមទៀតក្នុងការប្រើប្រាស់ភូមិសហគ្រាសឌីជីថលធុនតូចនិងមធ្យមដើម្បីសម្របសម្រួលវគ្គបណ្តុះបណ្តាលស្តីពីការគ្រប់គ្រងធុរកិច្ច,ពាណិជ្ជកម្មអេឡិចត្រូនិច,ការបង្កើតគេហទំព័រ, ច្បាប់បញ្ញត្តិស្តីពីផលិតផល និងធុរកិច្ច, ក៏ដូចជាការបង្កើនអត្ថប្រយោជន៍នៃកម្មវិធីគណនេយ្យអនឡាញ និងការលើកកម្ពស់អាជីវកម្មទាំងនេះ។ លោកម៉ាស៊ីហ្វ បានចាប់ផ្តើមវគ្គបង្វឹកម្នាក់ទល់ម្នាក់រៀងរាល់សប្តាហ៍នៅភូមិឌីជីថល។ រហូតដល់ពេលនេះ លោកបានធ្វើការងារជាមួយបុគ្គលចំនួន១២ រូប ភាគច្រើនគឺជាម្ចាស់អាជីវកម្មខ្នាតតូចក្នុងវិស័យចំណីអាហារ។ វគ្គបង្វឹកផ្ទាល់នៅភូមិឌីជីថលនេះគ្របដណ្តប់ប្រធានបទជាច្រើនអាស្រ័យលើសេចក្តីត្រូវការរបស់សិក្ខាកាម ហើយប្រធានបទដែលមានច្រើនមានក្នុងបណ្ឌិត្យសភាអាស៊ាននេះអាចឲ្យសិក្ខាកាមម្នាក់ៗរៀនទៅតាមសេចក្តីត្រូវការ និងចំណង់ចំណូលចិត្តរបស់ខ្លួនបានដោយងាយ។



## អ្នកនាង រ៉ាហ៊ីយូ ហេនីរ៉ាទី

ហិរញ្ញិកនៅសមាគមន៍សេវាកម្មអភិវឌ្ឍន៍សេវាកម្មធុរកិច្ចរួម (PLUT) សម្រាប់សហករធុរកិច្ចឥណ្ឌូនេស៊ី, ខេត្តយ៉ូកយ៉ាការតា, កោះជ្វាប៉ៃកកណ្តាល

**ប្រទេសឥណ្ឌូនេស៊ី**

*"សហ្រគាសធុនតូច និងមធ្យមត្រូវតែរៀនសម្របខ្លួន និងទទួលយកបច្ចេកវិទ្យាថ្មីៗដូចត្រមូវការទីផ្សារ។ វេទិកាអនឡាញនេះធ្វើឲ្យខ្ញុំ និងសហគ្រាសធុនតូច និងមធ្យមក្នុងតំបន់របស់ខ្ញុំរៀនអំពីបច្ចេកវិទ្យាថ្មីៗ និងឈានទៅកាន់ "ជីវភាពបែបឌីជីថល" រស់នៅក្នុងយុគ្គសម័យឌីជីថល"*

អ្នកនាងរ៉ាហ៊ីយូ ហេនីរ៉ាទី ហៅកាត់ថា ហេនី បានដឹងភ្លាមៗថាបណ្ឌិត្យសភាសហគ្រាសធុនតូចនិងមធ្យមអាស៊ាន (ឬបណ្ឌិត្យសភាអាស៊ាន) គឺជាអ្វីដែលសហគ្រាសធុនតូច និងមធ្យមដែលនាងធ្វើការជាមួយនៅស្រុកបានទុល, កោះជ្វាប៉ៃកកណ្តាលអាចទទួលអត្ថប្រយោជន៍បាន។ អ្នកនាងហេនី ដែលបច្ចុប្បន្នកំពុងធ្វើការនៅសមាគមន៍សេវាកម្មអភិវឌ្ឍន៍សេដ្ឋកិច្ចឥណ្ឌូនេស៊ី (ABDSI) នៅខេត្តយ៉ូកយ៉ាការតាទទួលការទាក់ទាញទៅកាន់បណ្ឌិត្យសភាអាស៊ានមុនគេនៅពេលដែលអ្នកនាងដឹងថាបណ្ឌិត្យសភាអាស៊ានមានវគ្គពិសេសៗរៀបចំទៅតាមដំណាក់កាលនៃការវិវត្តិរបស់អាជីវកម្ម គឺពីការចាប់ផ្តើមអាជីវកម្ម រហូតដល់ការត្រៀមខ្លួននាំចេញ។ អ្នកនាងហេនី ធ្វើការងារភាគច្រើនជាមួយម្ចាស់អាជីវកម្មស្ត្រីធុនតូចបំផុត និងធុនតូចក្នុងភូមិចំនួន១០ ក្នុងស្រុកបានទុល។ ភាគច្រើនគឺជាអាជីវកម្មផលិតអាហារសម្រន់ដូចជានំប៉ាក់ពៀ ជានំប្រចាំស្រុក ឬដំឡូងបារាំងចៀនតាមបែបផែនផ្សេងៗដ៏សម្បូរបែប។ អ្នកខ្លះទៀតផលិតក្រណាត់បាទីក។ បន្ទាប់ពីទទួលបានការបណ្តុះបណ្តាលនៅក្រុងហ្សាការតា អ្នកនាងហេនី បានចាប់ផ្តើមណែនាំវេទិកាអនឡាញនេះទៅកាន់សហគ្រិនស្ត្រីចំនួន ២៥ នាក់ទៀតដែលនាងធ្វើការជាមួយជាពិសេសវគ្គដែលនាងយល់ថាបានផ្តល់អំណាចដល់អាជីវកម្មស្ត្រីជាងគេគឺមានដូចជាមូលដ្ឋានគ្រឹះហិរញ្ញវត្ថុ, ទីផ្សារ,និងការគ្រប់គ្រងធុរកិច្ច និងភាពជាអ្នកដឹកនាំ។

មានបញ្ហាប្រឈមធ្ងន់ធ្ងរមួយចំពោះសហគ្រិនស្ត្រីដែលហេនី ធ្វើការងារជាមួយនោះគឺពួកគាត់ទទួលបន្ទុកការងារប្រចាំថ្ងៃក្នុងផ្ទះដូចគ្នានឹងការធ្វើអាជីវកម្ម ដូច្នេះពួកគាត់មានពេលតិចតួចណាស់ដើម្បីរៀនវគ្គនានានៅក្នុងបណ្ឌិត្យសភា។





ស្រដៀងគ្នានេះដែរ កង្វះបណ្តាញអ៊ីនធើណិតដើម្បីតភ្ជាប់ឲ្យបានងាយស្រួលក៏ជាឧបសគ្គធ្វើឲ្យពួកគាត់មិនអាចរៀនបានក្នុងពេលទំនេរ។ ដើម្បីជាដំណោះស្រាយអ្នកនាងហេនី បានបង្កើតសៀវភៅណែនាំមួយផ្សេងទៀតសម្រាប់វគ្គនានាក្នុងបណ្ឌិត្យសភាអាស៊ានដោយបានគូសបញ្ជាក់មេរៀនទាំងឡាយណាដែលនាងគិតថាបានផ្តល់អំណាចដល់ស្ត្រីជាពិសេសដូចជាវគ្គអំពីមូលដ្ឋានគ្រឹះហិរញ្ញវត្ថុ និងវគ្គផ្សេងៗទៀតផ្តោតលើជំនាញធ្វើការសម្រេចចិត្ត។

ដើម្បីដោះស្រាយបញ្ហាអ៊ីនធើណិតបន្ថែមទៀត អ្នកនាងហេនី បានសម្របសម្រួលក្រុមពិភាក្សាស្តីពីករណីសិក្សានានាផ្អែកលើវគ្គដែលនាងបានគូសបញ្ជាក់នៅក្នុងសៀវភៅណែនាំរបស់នាង។ ការសម្របខ្លួនបែបនេះបញ្ជាក់ថាអ្នកនាងហេនី មិនត្រឹមតែជំនះលើបញ្ហាដែលគ្មានអ៊ីនធើណិតប៉ុណ្ណោះទេ ប៉ុន្តែនាងក៏អាចបង្កើតតម្លៃបន្ថែម និងជ្រើសរើសវគ្គដែលពង្រឹងអំណាចដល់សហគ្រិនជាស្ត្រីថែមទៀត។

ទោះជាវេទិកាបណ្ឌិត្យសភាអាស៊ានប្រើតែភាសាអង់គ្លេសក្តី អ្នកនាងហេនី មានអារម្មណ៍ថាខ្លឹមសារនិងវគ្គផ្សេងៗនៅវេទិកានេះងាយស្រួលយល់គួរសមដែរ។ ក្នុងទស្សនៈរបស់នាងអ្នកប្រើប្រាស់គួរកេងចំណេញពីបណ្ឌិត្យអាស៊ានឲ្យបានច្រើនដើម្បីរស់នៅក្នុងយុគ្គសម័យឌីជីថលនេះប្រកបដោយជោគជ័យ។ ខណៈដែលសហគ្រិនស្ត្រីនៅក្នុងតំបន់ពិបាកស្វែងរកពេលវេលាសិក្សា ក៏ដូចជាត្រូវចេះបច្ចេកវិទ្យាថ្មីៗនោះ ពួកគេមានភាពបើកចំហទៅនឹងមធ្យោបាយឌីជីថលផ្សេងទៀតដើម្បីធ្វើឲ្យអាជីវកម្មពួកគេប្រសើរឡើង។ សហគ្រិនស្ត្រីទាំងនោះមានក្តីរំភើបក្នុងការប្រើប្រាស់បណ្តាញសង្គមដូចជាហ្វេសប៊ុក និងកម្មវិធីផ្ញើសាររហ័សសម្រាប់ទូរស័ព្ទទំនើបដូចជាវ៉តស៍អ៊ែប(Whatsapp) ជាដើម។

គាំទ្រដោយ

# អ្នកសម្របសម្រួលប្រកបដោយជំនាញ



បណ្ឌិត្យសភាអាស៊ានទទួលការគាំទ្រពីសំណាក់អ្នកសម្របសម្រួលប្រកបដោយជំនាញមួយក្រុមដែលត្រៀមខ្លួនជាស្រេចដើម្បីជួយលោកអ្នករៀនឲ្យចប់វគ្គសិក្សានានា។

អ្នកសម្របសម្រួលដែលសុទ្ធតែទទួលបានការបណ្តុះបណ្តាលត្រឹមត្រូវរបស់យើងអាចជួយលោកអ្នកទទួលបានអត្ថប្រយោជន៍ឲ្យបានច្រើនបំផុតពីបណ្ឌិត្យសភា។

យើងសូមលើកទឹកចិត្តអ្នកសម្របសម្រួលរបស់យើងឲ្យយល់ដឹងឲ្យច្បាស់អំពីវេទិកា ក៏ដូចជាអត្ថប្រយោជន៍នៃមុខងារនានារបស់បណ្ឌិត្យសភាមួយនេះ។ អ្នកសម្របសម្រួលរបស់យើងផ្សារភ្ជាប់គ្នាតាមបណ្តាញមួយឈ្មោះថាប្រេន ត្រាស់ ណិតវើក ដើម្បីឲ្យពួកគាត់ចែករំលែក និងផ្លាស់ប្តូរជំនាញ និងបទពិសោធន៍នៅកម្រិតប្រតិបត្តិការណ៍។ ប្រសិនបើលោកអ្នកមានបញ្ហាក្នុងការចូលទៅរៀនក្នុងបណ្ឌិត្យសភា ឬក៏លោកអ្នកចង់បណ្តុះបណ្តាលសហគ្រាសធុនតូច និងមធ្យមពីរបៀបប្រើប្រាស់បណ្ឌិត្យសភា លោកអ្នកអាចស្នើរសុំការជួយគាំទ្រពីសំណាក់អ្នកសម្របសម្រួលរបស់យើង។

# បណ្តាញប្រេន ត្រាស់

## បណ្ឌិត្យសភាសហគ្រាសធុនតូច និងមធ្យមអាស៊ាន

## ប្រទេសកម្ពុជា



## Chan Soly

**E.** ms.solychan@gmail.com
**M.** +855 96 333 0390

**Mastered Courses:**
- Social Entrepreneurship
- Business Email

## Chen Sopheap

**E.** sopheapchen@gmail.com
keiytambanhkhmer@gmail.com
**M.** +855 12 99 23 97

**Mastered Courses:**
- Selling Online
- Your Target Audience





## Chenda Clais

**E.** chenda.clais@gmail.com
**M.** +855 12 965 165

**Mastered Courses:**
- Strategic Planning
- Effective Leadership



## Heng Arunkakda

**E.** heng.arunkadka@gmail.com
**M.** +855 16 845 868

**Mastered Courses:**
- Hiring Staff
- Energy Efficiency: Do More for Less

## Heng Sothea

**E.** sothea.heng@gmail.com
**M.** +855 12 995 865

**Mastered Courses:**
- Strengthening Global Presence through Online Marketing





## Kim Channary

**E.** channary77@yahoo.com
**M.**+855 92 569 775

**Mastered Courses:**
- Marketing Benefits vs Features



## Koeung Sokkheng

E. sokkhengkoeung@yahoo.com
M. +855 12 469 231

**Mastered Courses:**
- Effective Leadership
- Managing Contact Information

## Lem Chansamrach

E. chansamrach.lem@gmail.com
M. +855 12 44 30 32

**Mastered Courses:**
- Finding Funding
- Hiring Staff





## Ly Huy

E. ahuy121@gmail.com
M. +855 86 707 355

**Mastered Courses:**
- Social Media Marketing
- Sales Forecasting

## Nanda Pok

E. poknanda@yahoo.com
M. +855 12 923 911

**Mastered Courses:**
- Your Target Audience





## Oeur Sothearoath

E. thearoath@yahoo.com:
s.oeur@creditbureaucambodia.com
M. +855 86 999 363; +855 89 999 363

**Mastered Courses:**
- Effective Business Websites

## Ourng Borinn

E. borinn.ourng@gmail.com
M. +855 78 921 921

**Mastered Courses:**
- Legal Aspects of Cross-Border E-commerce
- Strengthening Global Presence through Online Marketing



## Phay Sophal

**E.** phay.sophal@gmail.com
**M.** +855 92 607 102

**Mastered Courses:**
- Marketing Benefits vs Features
- Unique Value Proposition
- Legal Aspects of Cross-Border E-commerce





## Po Phymean

**E.** pophymean@yahoo.com
**M.** +855 17 973 788

**Mastered Courses:**
- Strategic Planning

## Pok Ponlok

**E.** pokponlok@gmail.com
**M.** +855 70 804 757

**Mastered Courses:**
- Strategic Planning
- Connecting Global Commerce



## Samnang Sou

**E.** samnangna@gmail.com
**M.** +855 11 626 333

**Mastered Courses:**
- Selling Online





## Socheata Touch

**E.** socheata-touch@inoted.asia
**M.** +855 12 671367

**Mastered Courses:**
- Sales Forecasting
- Effective Business Websites

## Sok Seang

**E.** sokseang@num.edu.kh
**M.** +855 12 918171

**Mastered Courses:**
- Effective Presentations
- Managing Contact Information



## Soth Chanrada

E. sothchanrada@gmail.com
M. +855 69 693 693

**Mastered Courses:**
- Business Email
- Effective Presentations



## Sotha Sothan



E. sothan.ccc@gmail.com;
sothanbizservices.ccc@gmail.com
M. +855 92 666 846

**Mastered Courses:**

## Sou Kimhong

E. sou_kimhong@yahoo.com
M. +855 17 303 979

**Mastered Courses:**
- Basics of Finance



## Sou Nay

E. mr.sounay@gmail.com
M. +855 16 677 318

**Mastered Courses:**
- Unique Value Proposition



## Thach Ket



E. thachket.thach@gmail.com
M. +855 98 919 087;
+855 77 484 544

**Mastered Courses:**
- Setting Prices

## Thong Songhak

E.songhakthong@gmail.com
M. +855 85 853 858

**Mastered Courses:**
- Cash Flow
- Inventory Management



## Toem Sinna

**E.** bmcchambercommerce@gmail.com
**M.** +855 17 834 283

**Mastered Courses:**
- Maximizing Capacity
- Presenting Data





## Lor Vicheka

**E.** newstyletailor27@gmail.com
**M.** +855 87 899 927

**Mastered Courses:**
- Cash Flow
- Setting Prices

## Chhorm Visith

**E.** visith.chhorm@gmail.com
**M.** +855 89 988 301

**Mastered Courses:**
- Profit and Loss
- Customer Relationship Management



ASEAN SME Academy

www.asean-sme-academy.org

USAID FROM THE AMERICAN PEOPLE

US-ASEANCONNECT partnering for sustainable, innovative, economic growth

US-ASEAN BUSINESS COUNCIL, INC

The ASEAN SME Academy is a multi-stakeholder effort under the US-ASEAN Business Alliance for Competitive SMEs, a collaboration among USAID, the US-ASEAN Business Council and ASEAN, and ASEAN's support is through the ASEAN Coordinating Committee on Micro, Small and Medium Enterprises.